ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៤ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

## ១- សេចក្តីផ្តើម

១-មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាលគឺៈ (១)-**ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, (២)-**ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង (៣)-**ដំណាក់កាលទី៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ ដូចនេះ ផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១, រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ ២០២១ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ ព្រមទាំងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។ ដូច្នេះ សារាចរណែនាំនេះ នឹងដាក់ចេញនូវក្របខណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ, អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។

២-ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកាដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយ ទាំងកម្រិតបច្ចេកទេស និងកម្រិតប្រតិបត្តិការ ក្នុងគោលដៅរួមចំណែក កាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

៣-ក្នុងឆ្នាំ ២០១៩ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ក្នុងអត្រា ៧,១% ដែលទ្រទ្រង់ដោយការបន្តរីកចម្រើននៃវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ទោះបីវិស័យកសិកម្មមានកំណើនអវិជ្ជមានយ៉ាងណាក្តី។ ការវាយតម្លៃជារួមបង្ហាញថា វិស័យឧស្សាហកម្មសម្រេចបានកំណើនក្នុងរង្វង់ ១១,៣% ដោយសារកំណើនខ្ពស់នៃអនុវិស័យសំណង់ និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ បើទោះបីជាអនុវិស័យកាត់ដេរមានកំណើនថមថយបន្តិច។ ជាមួយគ្នានេះ, វិស័យសេវាកម្មត្រូវបានវាយតម្លៃថាសម្រេចបានកំណើន ៦,២% ដោយសារកំណើនយឺតនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យអចលនទ្រព្យ ខណៈដែលអនុវិស័យលក់ដុំ-រាយបន្តមានកំណើនល្អប្រសើរ។ ចំណែកឯ វិស័យកសិកម្មត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន ០,៥% ដោយសារកំណើនធ្លាក់ចុះនៃអនុវិស័យចិញ្ចឹមសត្វ និងនេសាទ ខណៈដែលអនុវិស័យដំណាំមានកំណើនទាប។

៤-លើទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ, ក្នុងឆ្នាំ ២០១៩ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation Policy) ក្នុងគោលដៅបន្តពង្រឹងប្រសិទ្ធភាពចំណាយថវិកាជាតិ តាមរយៈការវិភាជឱ្យកាន់តែចំគោលដៅ និងកាត់បន្ថយចំណាយមិនចាំបាច់មួយចំនួន បន្ទាប់ពីអនុវត្តគោលនយោបាយ-វិត្ថារកម្មថវិកាក្នុងឆ្នាំ ២០១៨ ដែលជួយជំរុញកំណើនសេដ្ឋកិច្ចដល់ ៧,៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ។ ការប្រមូលចំណូលក្នុងស្រុកក្នុងឆ្នាំ ២០១៩ សម្រេចបានកំណើនខ្ពស់ក្នុងអត្រា ២៦,២% សមមូលស្មើនឹង ២៥,២២% នៃ ផ.ស.ស ដែលជាលទ្ធផលល្អប្រសើរលើសការរំពឹងទុកនៃចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ជាមួយគ្នានេះ ចំណាយថវិកាសរុបអនុវត្តបានប្រមាណ ២៥,៧៥% នៃ ផ.ស.ស ស្មើនឹងកំណើន ១៦,៧% ដែលក្នុងនោះបានផ្តល់លទ្ធភាពដល់ការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងពង្រីកការអនុវត្តគោលនយោបាយគាំពារសង្គមផងដែរ។ **ជារួម ឱនភាពថវិកាក្នុងឆ្នាំ ២០១៩ សម្រេចបានក្នុងរង្វង់ -០,៥៣% នៃ ផ.ស.ស** ល្អប្រសើរជាងការគ្រោងទុកក្នុងច្បាប់ថវិកា។

៥-ដោយឡែក សម្រាប់ឆ្នាំ ២០២០ សេដ្ឋកិច្ចកម្ពុជាបាននិងកំពុងទទួលរងនូវផលប៉ះទង្គិចធ្ងន់ធ្ងរបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលជាលទ្ធផលសេដ្ឋកិច្ចកម្ពុជាអាចមានកំណើនអវិជ្ជមាន ១,៩% ដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួន។ កត្តាសត្យានុម័តមួយចំនួនបង្ហាញថា ការខាតបង់នៃសេដ្ឋកិច្ចកម្ពុជាមានទំហំធំធេង រួមមាន៖ ១). ផលប៉ះពាល់ដែលកើតចេញពីវិបត្តិកូវីដ-១៩ នេះ មានវិសាលភាពជាសកល និងមានល្បឿនលឿនជាងការរំពឹងទុក, ២). វិស័យដែលអូសទាញកំណើនសេដ្ឋកិច្ចកម្ពុជាបាន និងកំពុងទទួលរងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ខណៈចន្លល់កំណើនថ្មីនៅមិនទាន់អាចមានលទ្ធភាពជំនួសបាននៅឡើយ, ៣). មុនទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិនេះ សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមជាមួយនឹងសញ្ញាថមថយរួចស្រេចទៅហើយ តាមរយៈការបាត់បង់ខ្លះៗនូវភាពប្រកួតប្រជែងដោយសារការព្យួរ EBA លើមុខទំនិញនាំចេញមួយចំនួន, ៤). លទ្ធភាព និងប្រសិទ្ធភាពនៃវិធានការគាំទ្រ ជាពិសេសផ្នែកហិរញ្ញវត្ថុរបស់កម្ពុជានៅមានកម្រិត, ៥). ជំហរអភិក្រម និងជម្រើសវិធានការរបស់កម្ពុជាផ្ទាល់ ត្រូវស្រប និងដើរទន្ទឹមនឹងប្រទេសជិតខាង និងតំបន់ដែលនេះហាក់កំពុងដាក់កំហិតបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា និង ៦). កម្ពុជាត្រូវត្រៀមសម្របខ្លួនជាមួយនឹងការប្រែប្រួលនៃនិន្នាការសកល ឬអាចជាប្រក្រតីកម្មថ្មី (new normal) ដែលនេះទាមទារនូវពេលវេលា និងការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ។

៦-ដូចនេះ ឆ្នាំ ២០២១ ដែលជាឆ្នាំទី ៣ នៃរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា និងក្នុងបរិបទនៃការគិតគូរស្តារកំណើនសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជនក្រោយវិបត្តិជំងឺកូវីដ-១៩ ទាមទារឱ្យរាជរដ្ឋាភិបាល

មានការប្តេជ្ញាចិត្តមោះមុតក្នុងការដាក់ចេញ និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការអន្តរាគមន៍សមស្របឱ្យបានទាន់ពេលវេលាក្នុងគោលដៅរក្សាលំនឹងសេដ្ឋកិច្ច តាមរយៈការបន្តការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម ព្រមទាំងការបន្តរក្សាលំនឹងជីវភាពប្រជាជន និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការបន្តបង្កើនភាពប្រកួតប្រជែង ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបន្តកែទម្រង់រចនាសម្ព័ន្ធ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដូចខាងក្រោម៖

## ២- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២១

### ២.១- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១

៧-ក្នុងឆ្នាំ ២០១៩ កន្លងមកនេះ កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានក្នុងអត្រា ៧,១% ដែលកំណើននេះត្រូវបានទ្រទ្រង់ដោយការបន្តសម្រេចកំណើនល្អប្រសើរនៃវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ទោះបីវិស័យកសិកម្មមានកំណើនអវិជ្ជមានយ៉ាងណាក្តី។ ទន្ទឹមនេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំស្ថិតក្នុងរង្វង់ ១,៨% និងអត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៥៥ រៀលក្នុងមួយដុល្លារអាមេរិក។ ការបន្តមានកំណើនខ្ពស់បែបនេះបានធ្វើឱ្យផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់ ១ ៧០០ ដុល្លារអាមេរិក។

៨-ដោយឡែកក្នុងឆ្នាំ ២០២០ នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ១,៩% ដែលជាអត្រាមិនធ្លាប់មានកន្លងមក ដោយសារការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩ ដែលបាន និងកំពុងធ្វើឱ្យតម្រូវការខាងក្រៅធ្លាក់ចុះយ៉ាងគំហុក និងរុញច្រានប្រទេសជាច្រើន ជាពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាប្រឈមនឹងកំណើនអវិជ្ជមាន, ដែលមុនពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករថាសម្រេចបានក្នុងរង្វង់ ៦,៥% សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០។ ផ.ស.ស. តាមថ្លៃបច្ចុប្បន្នឆ្នាំ ២០២០ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន ១១០ ៦៥៣ ប៊ីលានរៀល។

៩-សម្រាប់ឆ្នាំ ២០២១, សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងទុកថាអាចនឹងងើបឡើងវិញមកក្នុងអត្រាកំណើនក្នុងរង្វង់ ៣,៥% ហើយ ផ.ស.ស. តាមថ្លៃបច្ចុប្បន្នឆ្នាំ ២០២១ ត្រូវបានព្យាករថាមានចំនួន ១១៧ ៩៣៩ ប៊ីលានរៀល ដោយសារការរំពឹងទុកនៃការងើបឡើងវិញយឺតនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសការកើនឡើងក្នុងកម្រិតទាបនៃតម្រូវការខាងក្រៅ និងទំនុកចិត្តទីផ្សារក្នុងស្រុក។ ការរំពឹងទុកនេះ គឺស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ដោយត្រូវពឹងផ្អែកលើកត្តាសន្មតមួយចំនួន ដូចជា៖ ប្រសិទ្ធភាពនៃវិធានការគ្រប់គ្រងផលប៉ះពាល់ពីជំងឺកូវីដ-១៩ របស់កម្ពុជាផ្ទាល់, ក្នុងតំបន់ និងសកលលោក, លទ្ធភាពរកឃើញថ្នាំព្យាបាល ព្រមទាំងលទ្ធភាពផលិតនូវវ៉ាក់សាំងទ្រង់ទ្រាយធំ ក៏ដូចជាការអនុវត្តវិធានការដែលបានដាក់ចេញដើម្បីស្តារ និងស្រោចស្រង់សេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១ ត្រូវបានគាំទ្រដោយ៖

• វិស័យកសិកម្មត្រូវបានព្យាករថានឹងមានកំណើនក្នុងរង្វង់អត្រា ០,៩% ក្នុងឆ្នាំ ២០២០ និងងើបឡើងវិញបន្តិចក្នុងអត្រា ១,៦% ក្នុងឆ្នាំ ២០២១ ដោយសារការងើបឡើងវិញនៃអនុវិស័យចិញ្ចឹមសត្វ និងនេសាទ។ អនុវិស័យដំណាំ ត្រូវបានព្យាករថានឹងសម្រេចបានកំណើន ០,៨% ក្នុងឆ្នាំ ២០២០ និង ១,៨% ក្នុងឆ្នាំ ២០២១ រៀងៗគ្នា ដោយសារកំណើនល្អប្រសើរនៃផលិតកម្មកៅស៊ូ និងដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ខណៈដែលផលិតកម្មស្រូវបន្តកំណើនទាប ទោះបីងើបឡើងវិញបន្តិចធៀបនឹងឆ្នាំ ២០១៩។ ផលិតកម្មដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ដូចជា៖ ដំឡូងមី ស្វាយចន្ទី ស្វាយ ចេក ពោត និងបន្លែ ជាដើម ត្រូវបានរំពឹងថានឹងបន្តកំណើនល្អ ដោយសារការអនុវត្តវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មក្នុងស្រុក ការកើនឡើងនូវការវិនិយោគក្នុងស្រុក និងបរទេសលើការកែច្នៃផលិតផល និងការរំពឹងទុកនូវការកើនឡើងនៃការនាំចេញទៅទីផ្សារចិន ហុងកុង កូរ៉េខាងត្បូង និងប្រទេសអាស៊ានមួយចំនួន។ អនុវិស័យនេសាទត្រូវបានព្យាករថានឹងងើបឡើងវិញបន្តិចក្នុងអត្រា ១,៣% ក្នុងឆ្នាំ ២០២០ និង ១,៧% ក្នុងឆ្នាំ ២០២១ ដែលត្រូវបានជំរុញដោយកំណើននៃការវិនិយោគលើអនុវិស័យវារីវប្បកម្ម ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈការគាំទ្រផ្នែកហិរញ្ញប្បទានសម្បទាន ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាព និងគុណភាព។ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករថាអាចងើបឡើងវិញបន្តិចក្នុងរង្វង់អត្រា ១,១% ក្នុងឆ្នាំ ២០២០ និង ១,៦% ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនូវកំណើនការចិញ្ចឹមសត្វបែបពាណិជ្ជកម្មខ្នាតមធ្យម និងធំ ជាពិសេសការចិញ្ចឹមជ្រូក និងមាន់ ដែលជំរុញដោយភាពល្អប្រសើរនៃតម្លៃសត្វ ព្រមទាំងការងើបឡើងវិញនៃការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ។ ទោះជាយ៉ាងនេះក្តី, *ជារួម វិស័យកសិកម្មនៅជួបបញ្ហាប្រឈមជាលក្ខណៈរចនាសម្ព័ន្ធ ដូចជា៖ កំណើនផលិតភាពទាប ទាំងផលិតភាពពលកម្ម និងផលិតភាពដី ភាពនៅទន់ខ្សោយនៃការធ្វើពាណិជ្ជូបនីយកម្ម និងពិពិធកម្មកសិកម្ម កង្វះការកែច្នៃផលិតផលកសិកម្មឱ្យអស់ពីសក្តានុពលដើម្បីបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច ភាពមានកម្រិតនៃការសម្របសម្រួលស្ថាប័ន និងការធ្វើសុខដុមនីយកម្មគម្រោងនានា ទាំងក្នុងកម្រិតនៃការធ្វើផែនការសកម្មភាពនិងថវិកា និងកម្រិតនៃការអនុវត្ត។*

• វិស័យឧស្សាហកម្មត្រូវបានប៉ាន់ស្មានថាអាចមានកំណើនអវិជ្ជមាន ២,២% ក្នុងឆ្នាំ ២០២០ ដោយសារការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃអនុវិស័យកាត់ដេរ និងសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានរំពឹងថានឹងនៅបន្តកំណើនខ្ពស់។ ក្នុងឆ្នាំ ២០២១ វិស័យនេះត្រូវបានព្យាករថានឹងងើបឡើងក្នុងអត្រា ៤,១% ដោយសារការកើនឡើងវិញក្នុងកម្រិតទាបនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅតែបន្តកំណើនល្អប្រសើរ។ អនុវិស័យកាត់ដេរត្រូវបានប៉ាន់ស្មានថាអាចមានកំណើនអវិជ្ជមាន ៦,៧% ក្នុងឆ្នាំ ២០២០ ដោយសារការធ្លាក់ចុះយ៉ាងគំហុកនៃតម្រូវការខាងក្រៅដែលបណ្តាលមកពីការទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលជំងឺកូវីដ-១៩ ជាពិសេសលើប្រទេសដែលជាទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជា ដូចជា៖ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ ប៉ុន្តែ អនុវិស័យនេះត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាទាប ១,៦% ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនៃការងើបឡើងយឺតនៃតម្រូវការខាងក្រៅ ទន្ទឹមគ្នានឹងការជួបប្រឈមការប្រកួតប្រជែងកាន់តែខ្លាំងពីការដណ្តើមយកទីផ្សារដែលទើបនឹងងើបឡើងមកវិញបន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ត្រូវបានគ្រប់គ្រង រួមទាំងផលប៉ះពាល់ដែលបណ្តាលមកពី

ការដកប្រព័ន្ធអនុគ្រោះពន្ធ EBA លើមុខទំនិញមួយចំនួន, ការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងវៀតណាម និងសហភាពអឺរ៉ុប ព្រមទាំងកំណើនទាបនៃផលិតភាពពលកម្ម។ អនុវិស័យសំណង់ត្រូវបានប៉ាន់ស្មានថាអាចមានកំណើនអវិជ្ជមាន ៥,៣% ក្នុងឆ្នាំ ២០២០ ដោយសារការធ្លាក់ចុះរំហូរទុនវិនិយោគពីបរទេស ជាពិសេសប្រទេសចិន និងតម្រូវការសាងសង់អគារបម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ព្រមទាំងការធ្លាក់ចុះទំនុកចិត្តវិនិយោគក្នុងស្រុកដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩។ ប៉ុន្តែ អនុវិស័យនេះត្រូវបានរំពឹងថាងើបឡើងវិញជាមួយនឹងកំណើនទាបក្នុងអត្រា ៣,៣% ក្នុងឆ្នាំ ២០២១ ដោយហេតុថាអនុវិស័យនេះត្រូវការពេលវេលាដើម្បីស្តារទំនុកចិត្តសម្រាប់អ្នកវិនិយោគ។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានព្យាករថាអាចបន្តកំណើនខ្ពស់ក្នុងរង្វង់ ១៣,១% ក្នុងឆ្នាំ ២០២០ ដោយសារកំណើនខ្ពស់នៃការនាំចេញផលិតផលមិនមែនកាត់ដេរ ដូចជា កង់, គ្រឿងបង្គុំអេឡិចត្រូនិក និងអង្ករ ព្រមទាំង ការកើនឡើងផលិតកម្មក្នុងស្រុកសម្រាប់ការប្រើប្រាស់ក្នុងស្រុក ស្របពេលដែលការរាតត្បាតនៃជំងឺកូវីដ-១៩ ធ្វើឱ្យរាំងស្ទះដល់ការផ្គត់ផ្គង់ទំនិញនាំចូល។ សម្រាប់ឆ្នាំ ២០២១ អនុវិស័យនេះត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងរង្វង់ ១០,១% ដោយសារការពង្រីកមូលដ្ឋានផលិតកម្មផលិតផលមិនមែនកាត់ដេរនៃវិនិយោគដែលមានស្រាប់ ទាំងក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស, ការរំពឹងទុកនិន្នាការនៃការផ្លាស់ប្តូរទីតាំង (relocation) របស់រោងចក្រមួយចំនួនមកកម្ពុជា ទន្ទឹមគ្នានឹងការដាក់ចេញជាបន្តបន្ទាប់នូវគោលនយោបាយគាំទ្រវិស័យឯកជន ជាពិសេសការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម និងការលើកកម្ពស់សហគ្រិនភាព។ ជារួម *វិស័យឧស្សាហកម្មកម្ពុជាមានសក្តានុពលខ្ពស់ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច ប៉ុន្តែចាំបាច់ត្រូវពន្លឿនការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥", ជំរុញអនុវត្តយន្តការ "គណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម" ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗដែលមានលក្ខណៈអន្តរស្ថាប័ន និងរៀបចំ "ផែនការមេដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង" សំដៅផ្សារភ្ជាប់ខ្សែច្រវ៉ាក់តម្លៃតំបន់ និងសកល ក្នុងគោលដៅជំរុញពិពិធកម្មក្នុងវិស័យឧស្សាហកម្ម។*

- វិស័យសេវាកម្ម ត្រូវបានប៉ាន់ស្មានថាអាចធ្លាក់ចុះមកក្នុងអត្រាអវិជ្ជមាន ៣,០% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនូវកំណើនអវិជ្ជមាននៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន, អនុវិស័យលក់ដុំ-រាយ និងអនុវិស័យអចលនទ្រព្យ។ សម្រាប់ឆ្នាំ ២០២១ វិស័យនេះត្រូវបានព្យាករថានឹងកើនឡើងវិញក្នុងអត្រាកំណើនទាប ៣,៦% ដោយសារការរំពឹងទុកការងើបឡើងវិញក្នុងកម្រិតទាបនូវសកម្មភាពសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីវិបត្តិកូវីដ-១៩។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានប៉ាន់ស្មានថាអាចមានកំណើនអវិជ្ជមាន ៩,៧% ក្នុងឆ្នាំ ២០២០ ដោយសារការធ្លាក់ចុះយ៉ាងគំហុកនៃចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩។ ប៉ុន្តែ អនុវិស័យនេះត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រា ៣,៨% ក្នុងឆ្នាំ ២០២១ ដោយសារមានកំណើនវិជ្ជមានឡើងវិញ ប៉ុន្តែស្ថិតក្នុងកម្រិតទាបនៅឡើយទាំងទំហំ និងអត្រាកំណើន ដោយសារការធ្លាក់ចុះលទ្ធភាពក្នុងការធ្វើដំណើរកំសាន្ត ហើយអនុវិស័យនេះអាចត្រូវការរយៈពេលពី ២ ទៅ ៣ ឆ្នាំ ដើម្បីអាចងើបទៅរកទំហំដែលធ្លាប់មានមុនពេលមានវិបត្តិ។ ដូចនេះ *ដើម្បីបង្កើនទំនុកចិត្តភ្ញៀវទេសចរលើវិស័យទេសចរណ៍កម្ពុជាឡើងវិញ ចាំបាច់ត្រូវដោះស្រាយ*

*ប្រឈមនឹងកង្វះខាតការធ្វើពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍, ភាពមានកម្រិតនៃសេវាទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងស្ថាប័ន ព្រមទាំងការខាតបង់ចំណូល ដោយសារអវត្តមាននៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ (backward linkages) ទន្ទឹមនឹងបង្កើនការប្រកួតប្រជែងខ្ពស់ ទាំងក្នុងអំឡុងពេល និងក្រោយបរិការណ៍ជំងឺកូវីដ-១៩។* អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងមានកំណើនអវិជ្ជមាន ៤,០% ក្នុងឆ្នាំ ២០២០ ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះតម្រូវការប្រើប្រាស់ក្នុងស្រុក ដោយសារការធ្លាក់ចុះនៃអនុវិស័យសំខាន់ៗ ដែលជាប្រភពប្រាក់ចំណូលរបស់ប្រជាជន រួមមាន៖ វិស័យកាត់ដេរ, សំណង់, អចលនទ្រព្យ និងសណ្ឋាគារនិងភោជនីយដ្ឋានជាដើម ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ទោះជាយ៉ាងនេះក្តី អនុវិស័យនេះ ត្រូវបានរំពឹងទុកថានឹងងើបឡើងវិញក្នុងអត្រា ២,០% ក្នុងឆ្នាំ ២០២១ ប៉ុន្តែទាបជាងនិន្នាការធម្មតា ដោយសារឥទ្ធិពលនៃការថមថយចំណូលរបស់ប្រជាពលរដ្ឋក្នុងអំឡុងពេលមានវិបត្តិ ដែលនៅតែបន្តជះឥទ្ធិពលដល់តម្រូវការប្រើប្រាស់។ អនុវិស័យអចលនទ្រព្យ ត្រូវបានព្យាករថានឹងមានកំណើនអវិជ្ជមានក្នុងអត្រា ៥,១% ក្នុងឆ្នាំ ២០២០ និងរំពឹងថានឹងងើបឡើងវិញជាមួយនឹងអត្រាកំណើនទាប ២,៦% ឆ្នាំ ២០២១។ ការធ្លាក់ចុះនេះឆ្លុះបញ្ចាំង តាមរយៈការរំពឹងទុកពីការធ្លាក់ចុះនៃលំហូរទុនវិនិយោគពីចិន និងទំនុកចិត្តវិនិយោគក្នុងស្រុក ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ដោយឡែកក្នុងឆ្នាំ ២០២១ អនុវិស័យអចលនទ្រព្យត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងកម្រិតទាប ដោយសារតែការរំពឹងទុកនៃការកើនឡើងយឺតនៃលំហូរទុនវិនិយោគ និងសកម្មភាពសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស ដែលជំរុញសកម្មភាពអចលនទ្រព្យ និងតម្រូវការក្នុងស្រុក។ អនុវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ ត្រូវបានព្យាករថាមានកំណើនថមថយគួរឱ្យកត់សម្គាល់មកក្នុងរង្វង់អត្រា ០,៤% ក្នុងឆ្នាំ ២០២០ និងងើបឡើងវិញក្នុងអត្រាកំណើន ៥,៩% ក្នុងឆ្នាំ ២០២១។

• អត្រាអតិផរណា ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ២,៨% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកការកើនឡើងនៃតម្រូវការ (demand shock) ម្ហូបអាហារ និងផលិតផលផ្សេងទៀតនៅលើទីផ្សារ ស្របពេលដែលការផ្គត់ផ្គង់ត្រូវបានរំពឹងថានឹងថមថយ ខណៈដែលថ្លៃដឹកជញ្ជូនត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះទៅតាមនិន្នាការថ្លៃប្រេងលើទីផ្សារអន្តរជាតិ។ ក្នុងឆ្នាំ ២០២១ អត្រានេះត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៣,១% ដោយសារការរំពឹងទុកការកើនឡើងបន្តិចមកវិញនូវថ្លៃប្រេងអន្តរជាតិ។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងមានស្ថិរភាពក្នុងឆ្នាំ ២០២០ និង ២០២១ គឺស្ថិតក្នុងរង្វង់ ៤ ១០០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់-គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ។

• ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ទំហំ ១៧,៦% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកការធ្លាក់ចុះនៃការនាំចេញ និងការធ្លាក់ចុះនៃចំណូលជារូបិយប័ណ្ណ ដែលបានមកពីទេសចរអន្តរជាតិ មានល្បឿនលឿនជាងការធ្លាក់ចុះនៃ ផ.ស.ស.។ យ៉ាងណាមិញ, ទំហំនេះត្រូវបានព្យាករថានឹងរួមតូចបន្តិចមកត្រឹម ១៧,៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនៃការងើបឡើងវិញបន្តិចនូវការនាំចេញ និងវិស័យទេសចរណ៍។ ទុនបម្រុងអន្តរជាតិសរុបក្នុងឆ្នាំ ២០២០ ត្រូវបានរំពឹងថានឹងថយចុះមកត្រឹម ១៦ ៩៣៧ លានដុល្លារអាមេរិក ដោយសារការរីកធំនៃឱនភាពគណនីចរន្ត រួមផ្សំនឹង

ការរំពឹងទុកការធ្លាក់ចុះរំហូរទុនវិនិយោគពីបរទេស។ ទោះជាយ៉ាងនេះក្តី, ទំហំនេះនៅតែអាចធានាការនាំចូលបាន ៨,៥ ខែ ដោយហេតុថាការនាំចូលរបស់កម្ពុជាក៏នឹងត្រូវថមថយផងដែរ។ ក្នុងឆ្នាំ ២០២១ ទុនបម្រុងអន្តរជាតិសរុប ត្រូវបានព្យាករថានឹងកើនឡើង ១៦ ៩៨១ លានដុល្លារអាមេរិក និងធានាការនាំចូលបាន ៨ ខែ ។

១០-ជារួម ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃការគិតគូរស្តារកំណើនសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជនក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ជាក់ស្តែង ក្របខណ្ឌនេះមានគោលដៅគាំទ្រការជំរុញកំណើនសេដ្ឋកិច្ចឱ្យសម្រេចបានក្នុងរង្វង់ ៣,៥% ជាមួយនឹងអត្រាអតិផរណាទាបដែលអាចគ្រប់គ្រងបានក្នុងរង្វង់អត្រាប្រមាណ ៣,១% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ១០០ រៀលក្នុងមួយដុល្លារអាមេរិក។

## ២.២- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២១

១១-ក្នុងបរិការណ៍នៃការរាតត្បាតយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ត្រូវបានធ្វើវិចារណកម្ម ដើម្បីបង្វែរថវិកាឆ្ពោះទៅដោះស្រាយការងារអាទិភាពចំពោះមុខចំនួន ០៤ រួមមាន៖ ១). ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ២). រក្សាលំនឹងជីវភាពប្រជាជនក្នុងកម្រិតអប្បបរមាមួយ (មិនឱ្យអត់បាយ) ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងអ្នកបាត់បង់ការងារ, ៣). ខិតខំជួយឱ្យអស់លទ្ធភាព ដើម្បីឱ្យធុរកិច្ច និងអាជីវកម្មអាចរស់បាន និង ៤). រក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម។

ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២១ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**" មានគោលបំណងដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ តាមរយៈការជំរុញការនាំចេញឱ្យអស់ពីសក្តានុពល និងងាកពីការពឹងផ្អែកទាំងស្រុងលើតម្រូវការខាងក្រៅ មកពឹងផ្អែកមួយចំនួនលើតម្រូវការក្នុងស្រុក;
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ប្រកបដោយបរិយាប័ន្ន;
- បន្តអនុវត្តក្របខណ្ឌចំណាយអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាចំពោះមុខ និងហានិភ័យនានា ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ជំរុញការអនុវត្ត "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥";
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥;
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ប្រកបដោយប្រសិទ្ធភាពខ្ពស់សំដៅធានាបាននូវចីរភាពបំណុល;

• ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការនៃ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥" តាមរយៈការបន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងវិធានការជាក់លាក់ និងការបន្តវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, ថាមពល និងឌីជីថល;

• បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ;

• ជំរុញការធ្វើពិពិធកម្មផលិតផល, គោលដៅ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និង

• បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម។

១២-ជារួម ស្របគ្នានឹងបរិការណ៍សេដ្ឋកិច្ចដូចបានរៀបរាប់ខាងលើ ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងដោយឈរលើគោលការណ៍បន្តលើកកម្ពស់ប្រសិទ្ធភាពចំណាយ ទាំងក្នុងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ ព្រមទាំងរឹតបន្តឹងចំណាយមិនចាំបាច់ផ្សេងៗ ដើម្បីតម្រង់ទិសនៃការបែងចែក និងប្រើប្រាស់ធនធាន សំដៅធានាឱ្យបាននូវប្រក្រតីភាពនៃដំណើរការស្ថាប័នរដ្ឋ, បន្តអនុវត្តគោលនយោបាយគាំពារសង្គមជួយដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ, អនុវត្តកម្មវិធីសាច់ប្រាក់ពលកម្មជួយដល់អ្នកបាត់បង់ការងារ, បន្តផ្តល់អាទិភាពលើការពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ, បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងពន្លឿនការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, ថាមពល និងឌីជីថល ក្នុងន័យលើកកម្ពស់ភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។

១៣-ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងនៃក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ ២០២១ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ ២០២១ ដូចខាងក្រោម៖

### ២.២.១- ក្របខណ្ឌចំណូលថវិកាឆ្នាំ ២០២១

១៤-គម្រោងចំណូលថវិកាឆ្នាំ ២០២១ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំណូលសរុបក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ ២០២១ គ្រោងសម្រេចឱ្យបាន ១៨,៣៥% នៃ ផ.ស.ស. គឺថយចុះ ៥,៤៥ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ១៧,៨% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២០) ក្នុងនោះ ៖

• ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ១៨,១៧% នៃ ផ.ស.ស. គឺថយចុះ ៥,៤៦ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ១៨,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០។ **ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៨,០៥% នៃ ផ.ស.ស.គឺថយចុះ ២,៤៧ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ១៨,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ** ត្រូវគ្រោងសម្រេចឱ្យបាន ៧,៦៩% នៃ ផ.ស.ស. គឺថយចុះ ២,៧៣ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ២១,៣% ធៀបនឹង

ច្បាប់ថវិកាឆ្នាំ ២០២០, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,៤២% នៃ ផ.ស.ស. គឺថយចុះ ០,២៦ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៣,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០។

• **ចំណូលមូលធន**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន ០,១៩% នៃ ផ.ស.ស. គឺកើនឡើង ១៤,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០។

• ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៤,៦៣% នៃ ផ.ស.ស. គឺថយចុះ ០,៨៤ ពិន្ទុភាគរយ នៃ ផ.ស.ស. ឬថយចុះ ៩,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,៧៣% នៃ ផ.ស.ស.។

១៥-ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។

### ក.១- ផ្នែកចំណូលពន្ធដារ

១៦-វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០២១ រួមមាន៖

• **ការបន្តពង្រឹងមុខងារប្រតិបត្តិការស្នូល** រួមមានការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា ដោយ៖

- បន្តកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងរៀបចំយន្តការនៃការចុះបញ្ជីពន្ធដារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយក្រសួង-ស្ថាប័នផ្សេងៗ;
- អនុវត្តការចុះបញ្ជីបែបអេឡិចត្រូនិក (e-registration), ការដាក់លិខិតប្រកាសពន្ធបែបអេឡិចត្រូនិក (e-filing), និងការបង់ប្រាក់ពន្ធបែបអេឡិចត្រូនិក (e-payment) ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា;
- ជំរុញការផ្តល់សេវាចុះបញ្ជីឱ្យបានទាន់ពេលវេលា ស្របតាមកម្រងសេវាសាធារណៈ និងសម្រេចគោលដៅនៃការចុះបញ្ជីឱ្យបាន ២០% ក្នុងមួយឆ្នាំ;
- ជំរុញការចុះបញ្ជីអចលនទ្រព្យនៅរាជធានីភ្នំពេញ ឱ្យបានពេញលេញតាមទិន្នន័យដែលបានអង្កេតក្នុងឆ្នាំ ២០២០ និងបញ្ចប់ការធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យនៅតាមបណ្តាខេត្តដែលមានសក្តានុពល ក្នុងឆ្នាំ ២០២១;
- បង្កើនការបញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ ច្បាប់ បទប្បញ្ញត្តិ និងកាតព្វកិច្ចពន្ធដារឱ្យកាន់តែទូលំទូលាយដល់សាធារណៈជន តាមរយៈការបង្កើនការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន, ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់;
- ពង្រឹង និងពន្លឿនយន្តការបង្វិលសងអាករលើតម្លៃបន្ថែម តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ និងបន្តធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ e-filing និង e-payment;

- ○ បន្តបង្កើនការប្រមូលទិន្នន័យផ្ដុំព័ត៌មានពីគ្រប់ប្រភព និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពពាក់ព័ន្ធ តាមរយៈយន្តការផ្លាស់ប្ដូរព័ត៌មាន ក្នុងគោលដៅកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ និងពង្រឹងការធ្វើសវនកម្មតាមវិស័យដែលមានហានិភ័យខ្ពស់;
  - ○ បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់ហានិភ័យអ្នកជាប់ពន្ធ ដោយផ្អែកលើសៀវភៅណែនាំស្ដីពីវិធីសាស្ត្រក្នុងការកំណត់ហានិភ័យអ្នកជាប់ពន្ធ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការលើបទល្មើសពន្ធដារ;
  - ○ ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត ជាពិសេសពង្រឹងការតឹងទារបំណុលចំពោះអាជីវកម្មដែលមិនទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងអាជីវកម្មដែលមានសក្ដានុពល តាមរយៈការរៀបចំកម្មវិធីលើកទឹកចិត្តឱ្យអ្នកជាប់ជំពាក់បំណុលមកបង់បានលឿនជាងកាលកំណត់ ឬបន្ធូរបន្ថយឱ្យបង់ជាដំណាក់កាល;
  - ○ បន្តអនុវត្តវិធានការពាក់ព័ន្ធដែលបានដាក់ចេញ នៅក្នុងក្របខណ្ឌគោលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។
- **ការបន្តការពង្រឹងមុខងារគាំទ្រ** ដោយ ៖
  - ○ គិតគូរដាក់ចេញនូវវិធានការគោលនយោបាយអនុគ្រោះ ឬបន្ធូរបន្ថយផ្នែកពន្ធដារ និងការសម្រួលនីតិវិធីរដ្ឋបាលសារពើពន្ធមួយចំនួន ដើម្បីជួយដល់អាជីវកម្មក្នុងស្រុកនិងធុរកិច្ចអាចបន្តសកម្មភាពរបស់ខ្លួន និងជួយដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច;
  - ○ បន្តកិច្ចការរៀបចំបទប្បញ្ញត្តិស្ដីពីពន្ធដារ ដើម្បីសម្រួលដល់ការវិនិយោគ និងការប្រកបអាជីវកម្មរបស់អាជីវករ;
  - ○ ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើនសមត្ថភាពធ្វើសវនកម្មសំដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ;
  - ○ សិក្សា និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម (Big Data) និងចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធច្រកចេញចូលតែមួយនៃប្រព័ន្ធ National international Gateway និងប្រព័ន្ធទូទាត់ (Payment Gateway)។

## ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ

១៧-វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០២១ រួមមាន៖

- ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលនឹងអាចកើតមានក្នុងឆ្នាំ ២០២១ វិធានការគន្លឹះដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ ២០២១ ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមាន២ ផ្នែក និងផ្ដោតលើគោលដៅជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំ ២០២១ រួមមាន៖
- **ការបន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម** ដោយ៖
  - ○ បន្តកែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ដើម្បីជំរុញការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ

ដំណាក់កាលទី ៣, ប្រព័ន្ធគ្រប់គ្រងហានិភ័យគយ ដោយរៀបចំប្រព័ន្ធទទួលព័ត៌មានជាមុន និងអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;

- បន្តពង្រីកវិសាលភាព និងពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព;
- បន្តអនុវត្តការសម្រួលការបញ្ចេញទំនិញពីគយសម្រាប់វត្ថុធាតុដើម និងផលិតផលនាំចេញក្នុងវិស័យដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងវិស័យអាទិភាពនានា;
- កែសម្រួល និងដាក់ឱ្យអនុវត្តកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ តាមរយៈការផ្ដល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត;
- បន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ (ការងារតម្លៃគិតពន្ធគយ, ការងារចំណាត់ថ្នាក់ទំនិញ និងការងារវិធានដើមកំណើតទំនិញ), ការអនុវត្តនីតិវិធីគយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

• **ការបន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច** ដោយ ៖

- បន្តចូលរួមអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជា វិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម តាមរយៈ ១).ការពិនិត្យរកមុខទំនិញដើម្បីបញ្ចុះអត្រាពន្ធអាករនាំចូល, និង ២).ការលើកសំណើទៅក្រុមការងារតារាងពន្ធគយអាស៊ាន (AHTN task force) ក្នុងការញែកលេខកូដចំពោះបន្ទាត់ពន្ធណាដែលមានមុខទំនិញបម្រើច្រើនវិស័យ ដើម្បីជាមូលដ្ឋានអាចកំណត់អត្រាពន្ធគយខុសគ្នាឱ្យស្របតាមវិស័យនីមួយៗ;
- ពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករសម្រាប់គ្រប់វិស័យ និងមុខសញ្ញាដែលទទួលបានការអនុគ្រោះ;
- បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើ ១.)ចំណូលពន្ធគយ ដែលបាត់បង់ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា, ២.)ការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូល និង ៣.)ការអនុវត្តគោលនយោបាយទម្លាក់ថ្លៃអគ្គិសនី និងការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេងឥន្ធនៈ;
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់;
- បន្តអនុវត្តយុទ្ធសាស្ត្រគយស្ដីពីអនុលោមភាព និងការអនុវត្តច្បាប់ (enforcement strategy) ក្នុងនោះរួមទាំងការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការចែករំលែកព័ត៌មានពាក់ព័ន្ធបទល្មើសគយក្នុងកម្រិតទ្វេភាគី តំបន់ និងសកល, និងការចូលរួមគម្រោងប្រតិបត្តិការគយរួមគ្នា;

- បន្តលើកកម្ពស់អនុលោមភាព និងការអនុវត្តច្បាប់របស់ធុរជន តាមរយៈការផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីតម្លៃនៃវប្បធម៌សារពើពន្ធស្អាតស្អំ និងផលវិបាកនៃអំពើល្មើស និងអំពើរត់ពន្ធ និង
- រៀបចំផែនការដាក់លាក់ក្នុងការរៀបចំធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត ដើម្បីឆ្លើយតបនឹងតម្រូវការ ក៏ដូចជាការត្រៀមខ្លួនសម្រាប់ការវិវត្តនៃបច្ចេកវិទ្យាថ្មី និងការឈានឆ្ពោះទៅសម្រេចបាននូវអង្គភាពមួយដែលទំនើប។

**ក.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ**

១៨-វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ ២០២១ រួមមាន៖

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ឱ្យរឹតតែទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, បន្តធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ និងបន្តជំរុញការតភ្ជាប់ និងសន្ទានកម្មរវាង NRMIS និង FMIS ឱ្យបានពេញលេញ;
- បន្តអភិវឌ្ឍមុខងារប្រព័ន្ធ NRMIS បន្ថែមដូចជាការផ្តល់វិក្កយបត្រតាមអនឡាញ និងការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈការទូទាត់បែបអេឡិចត្រូនិក (E-payment) ដើម្បីលើកកម្ពស់ស្តង់ដារសេវាសម្រាប់បង់ចំណូលឱ្យមានភាពងាយស្រួល និងតម្លាភាព;
- បន្តពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ក្នុងប្រព័ន្ធក្រៅបណ្តាញ (offline) ដោយជំរុញការរៀបចំបញ្ជីក្នុងប្រព័ន្ធ និងការរៀបចំប័ណ្ណកម្មសិទ្ធិឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដើម្បីឈានដល់ការតភ្ជាប់ប្រព័ន្ធ SARMIS ជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យដទៃទៀត (online);
- បង្កើនសមត្ថភាពចរចាជាមួយភាគីពាក់ព័ន្ធ និងរៀបចំយន្តការគ្រប់គ្រងប្រភពចំណូល ដែលមានសក្តានុពលក្នុងវិស័យរ៉ែនិងថាមពល ដូចជាចំណូលពីសម្បទាន និងចំណូលពីការបែងចែកផលឱ្យមានប្រសិទ្ធភាព;
- ជំរុញការសិក្សា និងពិនិត្យលទ្ធភាពអភិវឌ្ឍន៍រមណីយដ្ឋានដែលមានសក្តានុពលថ្មីៗទាក់ទាញភ្ញៀវទេសចរ ដើម្បីបង្កើនទិសដៅទេសចរណ៍នៅកម្ពុជា;
- អនុវត្តយន្តការកំណត់ និងបង់កម្រៃសេវា រួមមានកម្រៃលេខទូរគមនាគមន៍, កម្រៃពីហ្វ្រេកង់ និងជំរុញការកែប្រែឡើងវិញនូវកម្រៃអាជ្ញាបណ្ណឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយ តាមបទដ្ឋានជាធរមាន;
- បន្តជំរុញការប្រើប្រាស់ទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ជាមូលដ្ឋានក្នុងការកំណត់ការបែងចែកប្រាក់ចំណូល និងសម្រាប់ផ្ទៀងផ្ទាត់ជាមួយចំណូលសារពើពន្ធ;
- បន្តពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ;

- ត្រៀមអនុវត្តគោលការណ៍រួម ស្របតាមតម្លៃទីផ្សារក្នុងការកៀរគរចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ និងពន្លឿនកិច្ចការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាជួលឱ្យបានរហ័ស;
- បន្តពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ខណៈបន្តការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ឱ្យអស់សក្ដានុពលដោយផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន;
- ដាក់ឱ្យប្រើប្រាស់ឯកសារគោល (Blueprint) ស្ដីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ និងជំរុញការអនុម័តច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;
- ដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ចាត់ចែងលើទ្រព្យសម្បត្តិ ដែលបានរឹបអូស;
- ពន្លឿនការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់
- ពន្លឿនការរៀបចំនូវក្របខណ្ឌគតិយុត្តថ្មីស្ដីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្ដែង;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រកៀរគរចំណូល ដោយតាមដាន និងរាយការណ៍ជាប្រចាំ;
- ពង្រឹងប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែន-សារពើពន្ធ ដើម្បីធ្វើការតាមដាន និងរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្ដីពីស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;

### ២.២.២- ក្របខណ្ឌចំណាយថវិកាឆ្នាំ ២០២១

១៩-ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងអនុវត្តអន្តរាគមន៍ចាំបាច់នានា, គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានកំណត់ និងវិភាជដូចខាងក្រោម៖

• **ចំណាយសរុបថវិការដ្ឋ** នៅឆ្នាំ ២០២១ នឹងកំណត់ក្នុងរង្វង់ ២៥,០៧% នៃ ផ.ស.ស. គឺថយចុះ ៥,០៦ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ១១,៣% ធៀបនឹងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២០) ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៣,៩៩% នៃ ផ.ស.ស. និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ១,៩៤% នៃ ផ.ស.ស. ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៨៦% នៃ ផ.ស.ស.។ **ចំណាយចរន្តថវិការដ្ឋ**ត្រូវកំណត់ក្នុងកម្រិត ១៥,៩៤% នៃ ផ.ស.ស. គឺថយចុះ ១,៩៧ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៥,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ដែលក្នុងនោះ៖

  - **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៨,៦% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៧៥% នៃ ផ.ស.ស. ។
  - **ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥១,៤% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,១៩% នៃ ផ.ស.ស. ដោយផ្ដោតលើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ដំណើរការងារ និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ការការពារ និងទប់ទល់នឹង

ជំងឺកូវីដ-១៩, ការសម្របខ្លួនទៅនឹងបរិការណ៍ថ្មី, ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម។

ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២១ ចំណាយមូលធនត្រូវបានគ្រោងប្រមាណ ៩,១៣% នៃ ផ.ស.ស. គឺថយចុះ ៣,០៩ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ២០,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ក្នុងគោលដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ, ជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ **ចំណាយសរុបថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យដូចខាងក្រោម៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៩៩% នៃ ផ.ស.ស. ថយចុះ ៦,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដោយផ្តោតលើការបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៨៩% នៃ ផ.ស.ស. ថយចុះ ៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដោយផ្តោតលើការបន្តយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ និងការបំពាក់មធ្យោបាយ និងបរិក្ខារចាំបាច់នានា ក្នុងបុព្វហេតុជានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ;
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,១៤% នៃ ផ.ស.ស. ថយចុះ ១១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ សំដៅបន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានសេវាសុខាភិបាល ក៏ដូចជាសុខុមាលភាពសង្គម តាមរយៈការគាំទ្រដល់កម្មវិធីមូលនិធិសមធម៌ និងការបន្តគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ជាពិសេសក្នុងបរិការណ៍ជំងឺកូវីដ-១៩។ ជាមួយគ្នានេះ បន្តការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់; និង
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៤២% នៃ ផ.ស.ស. ថយចុះ ៥,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដោយផ្តោតលើការបន្តជានាការអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន និងការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ក្នុងសង្គម ក្នុងនោះ ការបន្តពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង ដោយផ្តោតលើការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបន្តវិនិយោគសាធារណៈ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន ថាមពល និងឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩។
- ចំពោះកញ្ចប់ថវិកាសម្រាប់អន្តរាគមន៍លើផលប៉ះពាល់ពីជំងឺកូវីដ-១៩ រួមមាន ការផ្តល់ការបណ្តុះ-បណ្តាលជំនាញវិជ្ជាជីវៈដល់កម្មករ ការផ្តល់ការឧបត្ថម្ភដល់កម្មករក្នុងពេលពេលព្យួរការងារ កម្មវិធីសាច់ប្រាក់ពលកម្ម និងការផ្តល់ជំនួយសង្គមដល់ប្រជាពលរដ្ឋងាយរងគ្រោះជាដើម ត្រូវបាន

គ្រោងដោយឡែកក្នុងកម្រិតអប្បបរមាមួយ ក្នុងក្របខណ្ឌនៃចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ក្នុងករណីដែលជំងឺកូវីដ-១៩ នៅមានរហូតដល់ដើមឆ្នាំ ២០២១ ហើយបើពុំមានហេតុការណ៍នេះទេចំណាយនេះនឹងត្រូវផ្ទេរទៅបំពេញឡើងវិញសម្រាប់កញ្ចប់គម្រោងវិនិយោគ-ផ្ទាល់ ដែលត្រូវបានកាត់កង ដើម្បីរៀបចំជាគម្រោងសម្រាប់អនុវត្តនៅក្នុងផ្នែកចំណាយមូលធន ។

• **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវកំណត់ត្រឹម ១៥,០៨% នៃ ផ.ស.ស. ថយចុះ ១,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ដែលក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៨,០៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,២៤% នៃ ផ.ស.ស. និង**ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥១,៩៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៨៤% នៃ ផ.ស.ស.។

• **ចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិ** ត្រូវកំណត់ត្រឹម ១,៧២% នៃ ផ.ស.ស. ថយចុះ ២៩,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក ០,៥១% នៃ ផ.ស.ស. និងចំណាយ ក្រៅបន្ទុកបុគ្គលិក ១,២១% នៃ ផ.ស.ស. ដែលត្រូវប្រើប្រាសថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបមានប្រមាណ ០,៨៦% នៃ ផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិស្មើនឹង ០,៨៦% នៃ ផ.ស.ស.។

២០-ក្នុងក្របខណ្ឌនៃគោលដៅរក្សាលំនឹងសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចឡើងវិញ, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២១ ដូចខាងក្រោម ៖

• ត្រៀមកញ្ចប់ថវិកាសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗ ក្នុងវិបត្តិជំងឺកូវីដ-១៩ ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងជួយគាំទ្រទាន់ពេលវេលាលើកម្មវិធីសំណាញ់សុវត្ថិភាពដល់ក្រុមអ្នកងាយរងគ្រោះ និងរក្សាលំនឹងការងារជូនប្រជាពលរដ្ឋដែលប៉ះពាល់ពីវិបត្តិនេះ;

• រក្សាកម្រិតប្រាក់បៀវត្ស (បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ) របស់មន្ត្រីរាជការ ឱ្យស្មើនឹងកម្រិតដែលទទួលបានក្នុងឆ្នាំ ២០២០។ លើសពីនេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនដាច់ខាតនូវគោលការណ៍ជាធរមាន ក្នុងការជ្រើសរើសក្របខណ្ឌមន្ត្រីថ្មី ឱ្យស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍;

• បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព;

• បន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ;

• បន្តអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធ និងធនធានមនុស្ស;

• បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន និងពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីឈានទៅចាប់ផ្តើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្តល់ព័ត៌មានពីសមិទ្ធកម្ម;

• ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់អនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧;

• បន្តរឹតត្បិតលើចំណាយមិនចាំបាច់ និងការមិនអនុញ្ញាតឱ្យក្រសួង-ស្ថាប័នណាមួយ ចាយលើសពីឥណទានដែលអនុញ្ញាតដោយច្បាប់ថវិកាប្រចាំឆ្នាំ;

• បន្តពង្រឹងការរៀបចំស្តង់ដារប្រព័ន្ធគណនេយ្យសាធារណៈ និងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ព្រមទាំងលើកកម្ពស់ការអនុវត្តវិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមាន;

• បន្តពង្រឹងការអនុវត្តផែនការសកម្មភាពរបស់គោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗរួមមាន៖ ក).កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, គ).យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥, ឃ).យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣, ង).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ និង ច).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥;

• បន្តជំរុញការអនុវត្តយន្តការចូលរួមធ្វើសហហិរញ្ញប្បទាន (co-financing) និងចែករំលែកហានិភ័យ (risk sharing) ជាមួយវិស័យឯកជន;

• អនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់;

• រៀបចំគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងជំរុញប្រសិទ្ធភាពនៃការរៀបចំផែនការនៃការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសការគិតគូរ និងឈានទៅផ្សារភ្ជាប់រវាងគម្រោងស្ថាបនា និងជួសជុល និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធ ឱ្យបានទាន់ពេលវេលា;

• បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ដោយបន្តគោរពតាមគោលការណ៍គន្លឹះ ទាំងទំហំ និងកម្រិតពិតាន ដើម្បីចូលរួមជំរុញការតភ្ជាប់, និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល។ លើសពីនេះ បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈ៖ ១). ការអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ឱ្យកាន់តែមានភាពច្បាស់លាស់គ្រប់ដំណាក់កាល, ២).ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និង ៣).ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;

### ២.២.៣- ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ ២០២១

២១-ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និងផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ២,២៣% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ ៦,៧២% នៃ ផ.ស.ស. នៅក្នុងឆ្នាំ ២០២១។ ដូចនេះ រាជរដ្ឋាភិបាលនឹងត្រូវប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាលសរុបប្រមាណ ១,៣៦% នៃ ផ.ស.ស ដើម្បីមានលទ្ធភាពក្នុងការបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តទប់ទល់នឹងផលប៉ះពាល់នៃការអូសបន្លាយវិបត្តិនៃជម្ងឺកូវីដ-១៩ មកលើសេដ្ឋកិច្ច-សង្គម, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា។

## ៣- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២១

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ ២០២១

២២-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ ២០២០),
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ,
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

### ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២១

២៣-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំង**រដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ ស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ *សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២៤-គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំង**រដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី

និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០១៩ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២០ និងដោយផ្អែកលើថ្លៃឯកតានៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២៥-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ក្នុងកម្រិតនៃទំហំពិតានចំណាយគោលដែលបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), **ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០២១ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួនក្នុងកម្រិតកញ្ចប់ថវិកាដែលបានផ្តល់ជូនជាពិតានចំណាយគោលឆ្នាំ ២០២១ និងត្រូវអនុលោមទៅតាម គោលការណ៍ និង បណ្តាទិឆានការ** ដូចខាងក្រោម៖

ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)៖ នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍នៃការដំឡើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចជាតិនៅបន្តរងផលប៉ះពាល់អវិជ្ជមានពីជំងឺកូវីដ-១៩ ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២១ ត្រូវអនុវត្តគោលការណ៍លម្អិត ដូចខាងក្រោម៖

- **ចំនួនក្របខណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ និងត្រូវបញ្ជាក់អំពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័នអាចស្នើសុំប្រើប្រាស់ថវិកានោះដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានគុណវុឌ្ឍិ និងសមត្ថភាពជំនាញខ្ពស់ និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន ជាពិសេសសម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗរបស់ក្រសួង-ស្ថាប័ន,*

- ត្រូវគ្រោង**បៀវត្សមូលដ្ឋាន ដោយរក្សាសន្ទស្សន៍បៀវត្សមូលដ្ឋានស្មើនឹងកម្រិតឆ្នាំ ២០២០** ដោយផ្អែកតាមក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០២០ ព្រមទាំងតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងនៅក្នុងឆ្នាំ ២០២០,
- ត្រូវគ្រោង**ប្រាក់បំណាច់មុខងារ**របស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២០,
- ត្រូវគ្រោង**ចំនួនមន្ត្រីជាប់កិច្ចសន្យា មិនឱ្យលើសពីចំនួន** ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២០ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ស្របតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងដោយ**រក្សាស្មើនឹងកម្រិតឆ្នាំ ២០២០**,
- **ត្រូវផ្អាកការគ្រោងសម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការសម្រាប់ពិធីបុណ្យចូលឆ្នាំខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ សម្រាប់ឆ្នាំ ២០២១។**
- ចំពោះកញ្ចប់ថវិកាសម្រាប់ការបន្តកាត់បន្ថយគម្លាតប្រាក់សោធននិវត្តន៍រវាងអ្នកចូលនិវត្តចាស់ និងថ្មី នឹងត្រូវបានគ្រោងដោយឡែកនៅក្នុងចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗដូចខាងក្រោម៖

- កំណត់*ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់* ។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ការចំណាយសម្ភារផ្គត់ផ្គង់ និងថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។**

- *កំណត់ចំណាយមិនប្រចាំ ដោយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាព នៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។*

ចំណាយមិនជាប្រចាំ គឺជាចំណាយដែលមិនត្រូវការចំណាយជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍ សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែង។

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២១ ប៉ុន្តែត្រូវកត់សម្គាល់ថា ***កញ្ចប់ថវិកានៃពិតានចំណាយគោលនេះ មិនទទួលបានជាស្វ័យប្រវត្តិនោះទេ***។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ មានន័យថា ពិតានចំណាយគោលនៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សា នៅពេលចរចាថវិកា ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មី។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២១ មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវគ្រោងយ៉ាងច្រើនបំផុត ស្មើនឹងកម្រិតថវិកាអតិបរមានៃច្បាប់ឆ្នាំ ២០២០ ដែលបានធ្វើវិចារណកម្មចំណាយរួច (ស្របតាមសារាចរណែនាំអំពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយលើកទី ២ សម្រាប់អនុវត្តច្បាប់ស្តីពី**ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០)។ ប៉ុន្តែ ត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះមិនទទួលបាន**ជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និង**រដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ** ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក **សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ** ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាល**នៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០១៩ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២០ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិពណ៌។ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកាត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ ២០២០ ហើយលែងត្រូវការនៅក្នុងឆ្នាំ ២០២១ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ ២០២០។ លើសពីនេះ ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថាលែងមានសារៈសំខាន់ ដូចជា **សកម្មភាពចូលរួមតាំងពិពណ៌ពាណិជ្ជកម្ម និងពិពណ៌ទេសចរមួយចំនួនដែលលែងមានភាពចាំបាច់។** ក្នុងន័យនេះ **ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ** ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងមានយុត្តការណ៍អំពីភាពចាំបាច់ និងបន្ទាន់ មានការពន្យល់ និងផ្តល់អំណះអំណាងយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីកញ្ចប់ថវិកានៃពិតានចំណាយគោល ចាំបាច់ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានការកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែមសម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្ត ចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេស ជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកាក្នុងក្របខណ្ឌនៃ

កញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមលទ្ធភាពថវិកាជាក់ស្តែង។

- **ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព** ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាចទៅតាម និងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុងក្រសួង-ស្ថាប័ន** មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំង**រដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុង**ក្រសួង-ស្ថាប័នដដែល ឬទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញមួយ ទៅមន្ទីរជំនាញមួយទៀតនៃក្រសួង-ស្ថាប័នតែមួយ ក៏ដូចជាពីមន្ទីរនៃរដ្ឋបាលខេត្តមួយ ទៅមន្ទីរនៃរដ្ឋបាលខេត្តមួយទៀត** ក្នុងក្របខណ្ឌនៃវិស័យចំណាយតែមួយ។

**គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក ២១) និងចំណាយ ជួសជុល ស្តារ និងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១)៖** ពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់និងធារាសាស្ត្រ ដែលទទួលបានចំណាយមូលធនជាទៀងទាត់, ផ្អែកតាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ និងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវចាប់ផ្តើមធ្វើសមាហរណកម្មការរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំ ឱ្យមានសង្គតិភាពពេលវេលាជាមួយនឹងប្រតិទិននៃការរៀបចំគម្រោងថវិកាចំណាយចរន្ត ពោលគឺបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំដែលប្រើថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) និងថវិកាជំពូក ៦១ (ការងារជួសជុល និងថែទាំ) ត្រូវសម្រេចឱ្យបានទាន់ពេលវេលា សម្រាប់ការវេចខ្ចប់ជាមួយនឹងចំណាយចរន្ត នៅក្នុងសេចក្តីព្រាងច្បាប់ថវិកា។ ចំពោះ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលបានការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) ជាទៀងទាត់ដែរ ក៏ត្រូវចាប់ផ្តើមអនុវត្តសាកល្បងការធ្វើសមាហរណកម្មការរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំ សម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ រីឯ ការកំណត់អាទិភាពគម្រោង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សា តាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោង ដែលមាននៅក្នុងសារាចរនេះ។ ដោយឡែក សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលជាកម្មវត្ថុទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែក ត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងរៀបចំអាទិភាវូបនីយកម្មគម្រោង ស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលទៅតាម

លទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ។

សម្រាប់គម្រោងសាងសង់ ស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រឆ្នាំ ២០២១, ក្រសួង-ស្ថាប័ន ត្រូវផ្អែកលើគោលការណ៍កំណត់អាទិភាព ដើម្បីជាមូលដ្ឋានក្នុងការគ្រោងចំណាយវិនិយោគ ទៅតាមវិស័យដូចខាងក្រោម៖

- *វិស័យផ្លូវថ្នល់*
  - អាទិភាពទី១៖ ជួសជុល ស្តារ និងថែទាំផ្លូវជាតិគ្រប់ប្រភេទ ដើម្បីធានាចីរភាពនៃប្រព័ន្ធគមនាគមន៍ និងចរាចរ។
  - អាទិភាពទី២៖ ជួសជុល ស្តារ និងថែទាំផ្លូវខេត្ត និងផ្លូវជនបទសំខាន់ៗ ដែលមានលក្ខណៈជាឆ្អឹងខ្នងនៃប្រព័ន្ធគមនាគមន៍ ដែលបម្រើឱ្យការដឹកជញ្ជូន និងចរាចរ នៅកម្រិតមូលដ្ឋាន កម្រិតតំបន់ និងកម្រិតជាតិ។
  - អាទិភាពទី៣៖ គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី។
  - អាទិភាពទី៤៖ គម្រោងបន្តដែលត្រូវស្តាបនាដើម្បីបង្កើនឬបង្គ្រប់ប្រសិទ្ធភាពប្រើប្រាស់។
  - អាទិភាពទី៥៖ គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។
- *វិស័យធារាសាស្ត្រ*
  - អាទិភាពទី១៖ ជួសជុល ស្តារ និងថែទាំប្រព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ ជាពិសេសប្រព័ន្ធធារាសាស្ត្រ ដែលបានស្តាបនារួចដោយថវិកាជាតិ ឬថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។
  - អាទិភាពទី២៖ ស្តាបនាប្រឡាយមេ និង/ឬប្រឡាយរងបន្ថែម ដើម្បីពង្រីកឱ្យអស់សក្តានុពលគម្រោងប្រព័ន្ធធារាសាស្ត្រធំៗដែលត្រូវបានស្តាបនារួចដោយថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា។
  - អាទិភាពទី៣៖ ស្តាបនាបន្តប្រព័ន្ធធារាសាស្ត្រមិនទាន់អនុវត្តចប់ ដើម្បីឱ្យក្លាយជាប្រព័ន្ធធារាសាស្ត្រមានសក្តានុពលពេញលេញ។
  - អាទិភាពទី៤៖ គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។

ទន្ទឹមនេះ ក្រៅពីវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ, ការកំណត់អាទិភាពគម្រោងសម្រាប់វិស័យផ្សេងៗទៀតនឹងត្រូវផ្អែកលើអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២១ ដែលកំណត់នៅផ្នែក ២.២ នៃសារាចរណែនាំនេះ។

២៦-ទន្ទឹមនេះ ចំណាយចរន្ត និងចំណាយវិនិយោគរបស់ក្រសួង-ស្ថាប័នមួយចំនួននៅថ្នាក់ជាតិ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការអភិវឌ្ឍនៅមូលដ្ឋាន ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, និងក្រសួងធនធានទឹក និងឧតុនិយម នឹងត្រូវរក្សាមិនឱ្យមានកំណើន ឬអនុញ្ញាតឱ្យកើន

តិចតួច ឬកាត់ចេញមួយចំនួននូវប្រភេទចំណាយថវិកាសម្រាប់អន្តរាគមន៍ដល់ថ្នាក់មូលដ្ឋានផ្ទាល់ ដោយត្រូវអនុវត្តតាមគម្រោងសាច់ប្រាក់ពលកម្មរបស់រាជរដ្ឋាភិបាល និងមួយផ្នែកទៀតគឺទុកឱ្យឃុំ សង្កាត់ ធ្វើខ្លួនឯងវិញ ដូចជា ការជីកស្រះ ការជីកអណ្តូង ការធ្វើបង្គន់អនាម័យ ការជីកប្រឡាយដើងក្អែបនៅតាមឃុំ ជាដើម ។ល។ តាមរយៈមូលនិធិអភិវឌ្ឍឃុំ-សង្កាត់ ដែលសុទ្ធសឹងជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទដែរ។

២៧-**ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែមករានៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២១ របស់ខ្លួនចំនួនពីរច្បាប់ (០១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ០១ ច្បាប់ទៀត បញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា** ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

២៨-**ការរៀបចំផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន** ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យ និងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកាដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

២៩-ដោយឡែក ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក២១) និង

ចំណាយជួសជុល ស្ពាន និងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១) ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាន និងកំពុងអនុវត្តជាធរមាន។

៣០-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៩ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២១ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០១៩ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២០ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២១។*

៣១-ទន្ទឹមនេះ ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២០ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២១ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោម-ជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

៣២-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២១

៣៣-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សា និងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីធ្វើការបូកសរុបគម្រោងចំណូល-ចំណាយរៀបចំជាសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ដាក់ជូនគណៈរដ្ឋមន្ត្រី នៅក្នុងសប្តាហ៍ទី១ នៃខែ តុលា ឆ្នាំ ២០២០ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយដាក់ជូនរដ្ឋសភាឱ្យបាន**

មុនសប្តាហ៍ទី ១ នៃខែ វិច្ឆិកា ឆ្នាំ ២០២០ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០។

៣៤- ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២១ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដាក់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបាន សម្រាប់ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ ការចរចាថវិកាកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) និងតាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោម-សកម្មភាព) លើមូលដ្ឋាននៃគោលការណ៍ និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីធានាប្រសិទ្ធភាពនៃការវិភាជថវិកា ក្នុងកម្រិតនៃពិតានកញ្ចប់ថវិកាឆ្នាំ ២០២១ ដែលបានកំណត់ និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម ០,១ លានរៀល។

## ៤- សេចក្តីសន្និដ្ឋាន

៣៥-ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឱ្យបានជោគជ័យនូវគោលបំណងគោលនយោបាយ និងកម្មវិធី ដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ក្នុងបរិការណ៍នៃការបន្សាំទៅនឹងផលវិបាកនៃជំងឺកូវីដ-១៩ និងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងវិធានការចាំបាច់ និងបន្ទាន់នានា ក្នុងគោលបំណងដើម្បីរក្សាលំនឹងសេដ្ឋកិច្ច តាមរយៈការបន្តការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម, ការបន្តរក្សាលំនឹងជីវភាពប្រជាជន, ព្រមទាំងដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច តាមរយៈការបន្តបង្កើនភាពប្រកួត-ប្រជែង, ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបន្តកែទម្រង់រចនាសម្ព័ន្ធ។

៣៦-ទោះជាយ៉ាងណាក្តី ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀត

ប្រកបដោយធន្ធៈប្តូរប្តេជ្ញ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣៧-ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័នទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា)។

ថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង
"ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ